**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**សាលក្រមព្រហ្មទណ្ឌ**
**លេខ ៥៣ "អ ក្រ១១"**
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤
-សំណុំរឿងព្រហ្មទណ្ឌលេខ ១២៨៨
ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣
-សំណុំរឿងស៊ើបសួរលេខ ៩៨២
ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៣
-សំណុំរឿងជំនុំជម្រះលេខ ៣៨៣១
ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣

## ក្នុងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ វេលាម៉ោង ០២ និង ៣០ នាទី រសៀល នៅសាលសវនាការទី៨ ដោយមានសមាសភាពដូចខាងក្រោម៖

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

លោកស្រី [redacted] ជាប្រធានក្រុមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា
លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជីសវនាការ**

កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ **១២៨៨** ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] **មករា ហៅ អាឆ្វេល** ភេទប្រុស អាយុ១៦ឆ្នាំ កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរ កម្មករបិទក្រដាសបួមលូ ទីកន្លែងកំណើត ភូមិ[redacted] ខេត្តតាកែវ ទីលំនៅបច្ចុប្បន្ន ស្នាក់នៅភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ នៅលីវ ឪពុកឈ្មោះ ខែម "រស់" ម្ដាយឈ្មោះ [redacted]"រស់" កម្រិតវប្បធម៌ថ្នាក់ទី០៤ ជា អនីតិជន ទោសពីមុន គ្មាន។ (ក្រៅឃុំ) ។

ជាប់ចោទពីបទ៖ **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ ក្រមព្រហ្មទណ្ឌ។

-មេធាវីការពារសិទ្ធិជនជាប់ចោទ៖ លោកមេធាវី [redacted] និងលោកមេធាវី [redacted]។

-ជនរងគ្រោះឈ្មោះ [redacted] **សុគាន់ ហៅ ស្រីអូច** ភេទស្រី អាយុ១៣ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៩ មានអាសយដ្ឋាន ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] **ខណ្ណា:** ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ កើតថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩១។



Scanned with CamScanner

-មេធាវីការពារសិទ្ធិជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណីលោកស្រី [redacted]។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១០ និង៣០នាទីព្រឹក នៅចំណុច ផ្ទះគ្មានលេខ ភូមិតាព្រឹ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ មានករណី ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ដែលប្រព្រឹត្តដោយជនជាប់ចោទឈ្មោះ [redacted] មករា ហៅ អាគ្លស់ ភេទប្រុស កើតឆ្នាំ២០០៧។ មុនពេលកើតហេតុ ជនរងគ្រោះឈ្មោះ [redacted] សុភាន់ ភេទស្រី អាយុ១៣ឆ្នាំ បានដើរទៅចំណុចកើតហេតុខាងលើ ក្នុងគោលបំណងយក ប្អូនប្រុសត្រឡប់មកផ្ទះវិញ លុះពេលទៅដល់ស្រាប់តែជនជាប់ចោទ ឈ្មោះ [redacted] មករា បានស្ទុះមកទាញដៃជនរងគ្រោះ រួចផ្តួលជនរងគ្រោះទៅលើគ្រែក្នុងផ្ទះ និងបានចាប់អោប ហើយបឺជនរងគ្រោះឈ្មោះ [redacted] សុភាន់ ចូលទៅក្នុងបន្ទប់។ ពេលនោះជនរងគ្រោះឈ្មោះ [redacted] សុភាន់ បានព្យាយាមស្រែកឱ្យគេជួយ តែត្រូវជនជាប់ចោទចាប់ផ្ទឹបទៅលើគ្រែ រួចបានថើបថ្ពាល់ជនរងគ្រោះ និងបម្រុងនិងដោះខោអាវជនរងគ្រោះធ្វើសកម្មភាពរំលោភ ប៉ុន្តែត្រូវបានជនរងគ្រោះរើបំរាស់ និងខាំចំកញ្ចឹងករជនជាប់ចោទបណ្តាលឱ្យដាច់សាច់។ ភ្លាមនោះឪពុករបស់ជនរងគ្រោះបានមកទាន់ ហើយបានឃាត់ខ្លួន ជនជាប់ចោទប្រគល់ឱ្យសមត្ថកិច្ចធ្វើការសាកសួរតែម្តង រួចសមត្ថកិច្ចក៏បានកសាងសំណុំរឿងបញ្ជូនមកអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី។

-បានឃើញ របាយការណ៍សំយោគលេខ ០៤/២០២៣ រ.ប.ក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ១២៨៨ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ៩៧៩ អ.យ.គ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងស៊ើបសួរលេខ ៩៨២ ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៨៥៣ អ.យ.គ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០២៣ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤១៩១ "ជ" ដ.ង ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញ សំណុំរឿងជំនុំជម្រះលេខ ៣៨៣១ ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០២៣ របស់សាលាដំបូងរាជធានីភ្នំពេញ ។

## នាពេលសវនាការ

-ក្រឡាបញ្ជីអានកំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទឈ្មោះ [redacted] មករា នៅដំណាក់កាលចៅក្រមស៊ើបសួរថាៈបានការដដែល។ ខ្លួនសូមរក្សានូវចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចកាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ទុកជាបានការដដែល។ ខ្លួន និងឈ្មោះ [redacted] សុភាន់ ធ្លាប់ធ្វើជាសង្សារជាមួយគ្នាកាលពីមុនមក ប៉ុន្តែខ្លួនមិនដែលស្រឡាញ់គេនោះទេ មានតែគេទេដែលស្រឡាញ់ខ្លួនតែម្នាក់ឯង ព្រោះឈ្មោះ [redacted] សុភាន់ តែងតែមកលេង



Scanned with CamScanner

នៅផ្ទះខ្លួនជាញឹកញាប់ ហើយនាពេលកន្លងមក [redacted] និងឈ្មោះ [redacted] សុភាន់ តែងតែប្រលែងជាមួយគ្នារហូតមក។ លុះដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុភាន់ បានមកផ្ទះរបស់ខ្លួនស្ថិតនៅ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពេលនោះខ្លួនកំពុងតែដេកនៅលើអង្រឹងចុចទូរស័ព្ទម្នាក់ឯង ស្រាប់តែឈ្មោះ [redacted] សុភាន់ មកឆក់ទូរស័ព្ទពីដៃរបស់ខ្លួន ព្រោះឃើញខ្លួនកំពុងតែលេងឆាតជាមួយស្រីផ្សេង ខ្លួនក៏បានឆក់ទូរស័ព្ទដៃមកវិញ ស្រាប់តែឈ្មោះ [redacted] សុភាន់ បានខាំកខ្លួនតែម្តង។ ក្រោយមកខ្លួនក៏បានដើរចូលបន្ទប់របស់ខ្លួន ហើយឈ្មោះ [redacted] សុភាន់ ក៏បានមកតាម រួចបានចាប់បោចសក់ និងទះកំភ្លៀងខ្លួន ហើយខ្លួនក៏បានចាប់ដៃរបស់នាងទាំងពីរដើម្បីវាយតបវិញ ស្រាប់តែឪពុករបស់ឈ្មោះ [redacted] សុភាន់ មកដល់ហើយក៏បានហៅសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនតែម្តង។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ [redacted] វណ្ណៈ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១១ និង០០នាទី ពេលត្រឡប់ មកពីធ្វើការវិញ ខ្លួនមិនបានឃើញកូនស្រី និងកូនប្រុសនៅផ្ទះ ទើបខ្លួនចំដើររកកូន ស្រាប់តែឃើញកូនប្រុស កំពុងអង្គុយចុចទូរស័ព្ទម្នាក់ឯងនៅផ្ទះមួយកន្លែងដែលមានចម្ងាយពីផ្ទះរបស់ខ្លួនប្រហែល៥០ម៉ែត្រ លុះពេលដើរទៅក្បែរកូនប្រុសខ្លួនក៏សួររកកូនស្រី ម្នាក់ទៀត ភ្លាមនោះកូនប្រុសរបស់ខ្លួនក៏ចង្អុលទៅបន្ទប់ផ្ទះមួយនោះ បន្ទាប់មកខ្លួនក៏ដើរចូលទៅមើល ស្រាប់តែឃើញកូនស្រីរបស់ខ្លួនកំពុងនៅពីក្រោមជនត្រូវចោទឈ្មោះ [redacted] មករា ដែលកំពុងប្រតាយប្រតប់គ្នាទៅវិញទៅមក ភ្លាមនោះខ្លួនក៏ចាប់ទាញយកកូនស្រីមកខាងក្រៅ ក្រោយមកខ្លួនក៏សួរនាំទៅជនត្រូវចោទឈ្មោះ [redacted] មករា តែជនត្រូវចោទបែរជាឆ្លើយថាប្រលែងគ្នាលេងទៅវិញ។ ក្រោយមកខ្លួនបានសួរនាំកូនស្រីរបស់ខ្លួន បានឆ្លើយថា ជនត្រូវចោទឈ្មោះ ខន មករា បានចាប់អោបនាងពីក្រោយ ហើយទាញចូលក្នុងបន្ទប់ប៉ុនប៉ងរំលោភសេពសន្ថវៈ បន្ទាប់ពីឮដូចនេះ ខ្លួនក៏ឃាត់ខ្លួនជនត្រូវចោទ រួចដាក់ពាក្យបណ្តឹងតែម្តង។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់ចម្លើយជនរងគ្រោះឈ្មោះ [redacted] សុភាន់ នៅដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ថា: កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនបានស្គាល់ជនត្រូវចោទឈ្មោះ [redacted] មករា ដែលស្នាក់នៅក្បែរបន្ទប់ជួលរបស់ខ្លួនដែរ ហើយជនត្រូវចោទឈ្មោះ [redacted] មករា និងខ្លួន គឺគ្រាន់តែជាអ្នករាប់អានគ្នាធម្មតា តែប៉ុណ្ណោះ ពុំមានចិត្តស្រលាញ់គ្នាទេ។ កន្លងមកជនត្រូវចោទឈ្មោះ [redacted] មករា បានប្រាប់ថាស្រលាញ់ខ្លួន តែខ្លួនតបវិញថា មនុស្សប្រុសម្នាក់មិនអាចស្រលាញ់មនុស្សស្រី០២នាក់បានទេ។ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១០ និង៣០នាទី ប្អូនប្រុសរបស់ខ្លួនបានដើរទៅលេងផ្ទះរបស់ជនត្រូវចោទ ឈ្មោះ [redacted] មករា ឃើញដូចនេះខ្លួនក៏ដើរសំដៅទៅយកប្អូនត្រឡប់មកផ្ទះវិញ តែពេលទៅដល់ស្រាប់ជនត្រូវចោទឈ្មោះ [redacted] មករា ចាប់ដៃខាងស្តាំរបស់ខ្លួនជាប់ ភ្លាមនោះខ្លួនបានក្រវាសដៃចេញ និងព្យាយាមរើបំរាស់ តែជនត្រូវចោទមិនព្រមលែងដៃរបស់ខ្លួនឡើយ ហើយខ្លួនក៏ស្ទុះទៅចាប់បង្គោលអង្រឹងដែលនៅពីមុខផ្ទះ របស់ជនត្រូវចោទជាប់ តែជនត្រូវចោទព្យាយាមប្រលេះដៃរបស់ខ្លួនចេញពីបង្គោលអង្រឹងនោះ បណ្តាលឱ្យស្នាមជាំលើកដៃទាំងសងខាង។ បន្ទាប់មកជនត្រូវចោទឈ្មោះ [redacted] មករា បានទាញខ្លួនផ្តួលទៅលើគ្រែមុខផ្ទះ រួចចាប់អោបខ្លួនហើយលើកបីចូលទៅក្នុងបន្ទប់ដេករបស់ជនត្រូវចោទ ភ្លាមនោះខ្លួនបានស្រែកឱ្យបងជីដូនមួយរបស់ជនត្រូវចោទឈ្មោះ រ៉ែត ដែលកំពុងលាងចាននៅក្បែរនោះ ប៉ុន្តែគាត់ធ្វើជាមិនចាប់អារម្មណ៍។ បន្ទាប់មកជនត្រូវចោទទាញខ្លួនចូលទៅដល់ក្នុងបន្ទប់ដេក ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] មករា បានបិទភ្លើងបណ្តាលឱ្យងងឹត តែមិនបានទាញទ្វាបន្ទប់បិទនោះទេ រួចជនត្រូវចោទក៏ចាប់ដៃទាំងសងខាងរបស់ខ្លួន ផ្អឹបទៅលើគ្រែ ហើយបានព្យាយាមថើបថ្ពាល់ទាំងសងខាងរបស់ខ្លួន តែខ្លួនព្យាយាមរើបំរាស់ ហើយខាំកញ្ចឹងក ខាងឆ្វេងរបស់ជនត្រូវចោទ



Scanned with CamScanner

បណ្តាលឱ្យដាច់សាច់ ប៉ុន្តែជនត្រូវចោទនៅតែបន្តសកម្មភាពដោះខោអាវរបស់ខ្លួនចេញ ហើយភ្លាមនោះឪពុករបស់ខ្លួនបានមកទាន់ រួចក៏ទូរស័ព្ទហៅសមត្ថកិច្ចឱ្យមកឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] មករា តែម្តង។

-ក្រឡាបញ្ជីអានកំណត់ហេតុស្តាប់សាក្សីឈ្មោះ [redacted] ប៊ុន ហៅ អាប៊ែត នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ថា៖ កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ ខ្លួនបានចូលមកធ្វើការជាបុគ្គលិកបួមលក់ម្ហូបក្នុងហាងរបស់ប្អូនជីដូនមួយរបស់ខ្លួនដែលជាជនត្រូវចោទឈ្មោះ [redacted] មករា ដែលមានទីតាំងនៅស្ថិតនៅភូមិតាឡី សង្កាត់ផ្សា ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ចាប់តាំងពីខ្លួនចូលមកធ្វើការបានរយៈពេលប្រហែលកន្លះខែមកនេះ ខ្លួនតែងតែឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ មកលេងនៅកន្លែងធ្វើការរបស់ខ្លួនជាមួយនិងប្អូនប្រុសអាយុប្រហែល០៤ឆ្នាំ ហើយក៏ធ្លាប់ឃើញលេងសើចជាមួយនឹងជនត្រូវចោទឈ្មោះ [redacted] មករា ចំនួន៣ ទៅ៤ដងមកហើយ។ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០៨ និង០០នាទីព្រឹក ពេលខ្លួនកំពុងអង្គុយលាងចាននៅខាងមុខផ្ទះ ស្រាប់តែឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ បានមកលេងកន្លែងធ្វើការរបស់ខ្លួន បន្ទាប់មកឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ ដើរមកយកប្អូនប្រុសរបស់នាង និងឃើញជនរងគ្រោះ លេងសើចជាមួយជនត្រូវចោទឈ្មោះ [redacted] មករា ហើយពួកគេបាននិយាយលេងគ្នាជាច្រើនដងនៅលើគ្រែមុខផ្ទះ។ ឃើញដូច្នេះខ្លួនក៏និយាយណែនាំជនត្រូវចោទថា កុំឱ្យធ្វើអញ្ចឹងព្រោះគេជាស្រីតែជនត្រូវចោទមិនស្តាប់ឡើយ ហើយជនត្រូវចោទបានចាប់អោបជនរងគ្រោះពីក្រោយខ្នង រួចទាញចូលទៅក្នុងបន្ទប់បាត់ទៅ តែពេលនោះខ្លួនមិនបានចាប់អារម្មណ៍ទេ ព្រោះគិតថាពួកគេលេងសើចជាមួយគ្នាតែប៉ុណ្ណោះ លុះក្រោយពីលាងចានរួច ខ្លួនក៏ដើរទៅដេកនៅខាងក្រោយផ្ទះបាត់ទៅ។

-ក្រឡាបញ្ជីអានលិខិតដកពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ ថា៖ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ខ្លួនបានប្តឹងលើឈ្មោះ [redacted] មករា ភេទប្រុស អាយុ១៦ឆ្នាំ ករណីប៉ុនប៉ងរំលោភលើកូនស្រីរបស់ខ្លួន ហើយក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន និងបញ្ជូនខ្លួនមកសាលាដំបូងរាជធានីភ្នំពេញ ដើម្បីចាត់ការបន្តតាមនីតិវិធីតែម្តង។ ប៉ុន្តែក្រោយពីបានដាក់ពាក្យប្តឹងរួច ខ្លួនក៏សាកសួរកូនស្រីរបស់ខ្លួន ពីដំណើររឿងដែលកើតឡើងនោះយ៉ាងម៉ត់ចត់ដែរ ហើយកូនស្រីរបស់ខ្លួនបានប្រាប់ថាឈ្មោះ [redacted] មករា បានចាប់ដៃ ចាប់ជើងរបស់ខ្លួន ប៉ុន្តែមិនបានធ្វើអ្វីលើសពីនេះទេ។ មួយវិញទៀតឪពុកម្តាយរបស់ឈ្មោះ [redacted] មករា បានសុំទោស និងសងសំណងដល់ខ្លួន រួចរាល់ហើយ ហេតុដូច្នេះខ្លួនសុំដកពាក្យបណ្តឹងលើឈ្មោះ [redacted] មករា ចាប់ពីពេលនេះតទៅ។

-ក្រឡាបញ្ជីអានកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៥០២ រ.វ.ត/២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់សាលាដំបូង និងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ រួមមាន៖ ទូរស័ព្ទចំនួន ០១ (មួយ) គ្រឿង ម៉ាក OPPO ពណ៌ទឹកប៊ិច បែកអេក្រង់ គុណភាពចាស់ (មិនដំណើរការ) ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដែលមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ [redacted] មករា និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិដើមបណ្តឹង និងជនរងគ្រោះ

-លោកស្រីមេធាវីការពារសិទ្ធិដើមបណ្តឹង និងជនរងគ្រោះ បានសន្និដ្ឋានការពារថា៖ តាមការពិនិត្យចម្លើយរបស់ជនជាប់ចោទ និងចម្លើយរបស់ជនរងគ្រោះ គឺមានចម្លើយប្រហាក់ប្រហែលគ្នា ដែលអាចបញ្ជាក់ពីសកម្មភាព និងចេតនាចាប់រំលោភសេពសន្ថវៈលើជនរងគ្រោះ ដូចជាការបញ្ជាក់ពីស្លាកស្នាមជាំលើកដៃរបស់ជនរងគ្រោះ, ស្នាមខាំលើករបស់ជនជាប់ចោទ, ការចាប់អោបជនរងគ្រោះពីក្រោយ, ការចាប់ជនរងគ្រោះចូលក្នុងបន្ទប់តែពីរនាក់ ព្រមទាំង

បិទភ្លើងបន្ទប់ ទាំងនេះជាចំណុចស៊ីសង្វាក់គ្នាថា បញ្ជាក់ពីចេតនាទុច្ចរិតមានបំណងរំលោភលើជនរងគ្រោះ មិនមែនជាសកម្មភាពប្រលែងគ្នាលេងនោះទេ។ ប៉ុន្តែដោយសារតែឪពុករបស់ជនរងគ្រោះមកបង្អាក់សកម្មភាពរបស់ជនជាប់ចោទទាន់ពេលវេលា ទើបជនជាប់ចោទមិនអាចបន្តសកម្មភាពបំពានផ្លូវភេទលើជនរងគ្រោះបាន។ ដូចនេះខ្លួនស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ ចំពោះសំណងរដ្ឋប្បវេណីខ្លួនមិនទាមទារទេ ព្រោះដើមបណ្តឹងរដ្ឋប្បវេណី ដែលជាកូនក្តីខ្លួនបានដកពាក្យបណ្តឹងរដ្ឋប្បវេណីរួចហើយ។

## សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា៖ តាមការស្តាប់ចម្លើយនាពេលសវនាការ និងតាមការពិនិត្យភស្តុតាងក្នុងសំណុំរឿង តំណាងអយ្យការសុំលើកពីទំនាក់ទំនងរបស់ជនជាប់ចោទ និងជនរងគ្រោះ ដែលធ្លាប់មានទំនាក់ទំនងគ្នាពីមុនមក នេះបើយោងតាមចម្លើយសាក្សីឈ្មោះ [redacted] ប៊ុន ហៅ អាប៉ែត ដែលបានឆ្លើយថា ចាប់តាំងពីខ្លួនចូលមកធ្វើការបានរយៈពេលប្រហែលកន្លះខែមកនេះ ខ្លួនតែងតែឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ មក លេងនៅកន្លែងធ្វើការរបស់ខ្លួនជាមួយនិងប្អូនប្រុសអាយុប្រហែល ០៤ឆ្នាំ ហើយក៏ធ្លាប់ឃើញលេងសើច ជាមួយនឹងឈ្មោះ [redacted] មករា ចំនួន៣ ទៅ៤ដងមកហើយ។ តែបើពិនិត្យលើសកម្មភាពនៅថ្ងៃកើតហេតុ គឺមានសកម្មភាពមួយចំនួនរបស់ជនជាប់ចោទមានការប៉ះពាល់ដល់ផ្នែកផ្លូវភេទ ដូចជា ការចាប់អោបជនរងគ្រោះពីក្រោយ, ការទាញខ្លួនផ្តួលទៅលើគ្រែមុខផ្ទះ និងជនជាប់ចោទបានអូសដៃជនរងគ្រោះចូលបន្ទប់ បិទភ្លើងក្នុងបន្ទប់ នៅតែពីរនាក់ក្នុងបន្ទប់ស្ងាត់ ដូចនេះមិនអាចបញ្ជាក់ពីការយល់ព្រមរបស់ជនរងគ្រោះនោះទេ គឺជនជាប់ចោទមានចេតនាបំពានផ្លូវភេទលើជនរងគ្រោះពិតមែន។ តំណាងអយ្យការនៅតែតម្កល់បទចោទប្រកាន់លើជនជាប់ចោទពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ ក្រមព្រហ្មទណ្ឌ និងប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

## សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-លោកមេធាវីការពារសិទ្ធិជនជាប់ចោទបានសន្និដ្ឋានការពារថា: តាមការស្តាប់ចម្លើយពីគ្រប់ភាគីទាំងអស់ គឺជនរងគ្រោះ និងជនជាប់ចោទ គឺជាមិត្តនឹងគ្នា ធ្លាប់មានទំនាក់ទំនងជាមួយគ្នាពីមុនមក លើសពីនេះជនរងគ្រោះតែងតែមកប្រលែងលេងជាមួយជនជាប់ចោទជាញឹកញាប់។ ដូចនេះបើពិនិត្យលើធាតុសត្យានុម័ត និងអត្តនោម័ត គឺជន ជាប់ចោទ មិនបានប្រើហិង្សាលើជនរងគ្រោះទេ មានតែជនរងគ្រោះខាំកជនជាប់ចោទ ហើយម្យ៉ាងវិញទៀត ថ្វីត្បិតតែជនជាប់ចោទ និងជនរងគ្រោះនៅក្នុងបន្ទប់ជាមួយគ្នាពិតមែន តែជនជាប់ចោទមិនបានបិទទ្វារបន្ទប់ទេ គឺចំហរទ្វារជាសាធារណៈ ដូចនេះជនជាប់ចោទគ្មានបំណងណាមួយ បំពានផ្លូវភេទលើជនរងគ្រោះទេ ហើយតាមលិខិតដកពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២៣ របស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] វណ្ណៈ បានបញ្ជាក់ថា: ក្រោយពីបានដាក់ពាក្យប្តឹងរួច ខ្លួនក៏សាកសួរកូនស្រីរបស់ខ្លួន ពីដំណើររឿងដែលកើតឡើងនោះយ៉ាងម៉េចដែរ ហើយកូនស្រីរបស់ខ្លួនបានប្រាប់ថាឈ្មោះ [redacted] មករា បានចាប់ដៃ ចាប់ជើងរបស់ខ្លួន ប៉ុន្តែមិនបានធ្វើអ្វីលើសពីនេះទេ។ ដូចនេះគ្មានចំណុចណាមួយច្បាស់លាស់បញ្ជាក់ថា ជនជាប់ចោទប្រព្រឹត្តដូចការចោទប្រកាន់នោះទេ គ្រប់យ៉ាងកើតចេញពីសន្និដ្ឋានរបស់ដើមបណ្តឹង។ ហេតុនេះខ្លួនសុំឱ្យតុលាការសម្រេចឱ្យជនជាប់ចោទរួចផុតពីការចោទប្រកាន់ ព្រោះថាវិមតិសង្ស័យជាប្រយោជន៍របស់ជនជាប់ចោទគ្រប់ពេល និងជនជាប់ចោទគ្មានចេតនាប្រព្រឹត្តបទល្មើសនោះទេ។



Scanned with CamScanner

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនរងគ្រោះ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិដើមបណ្តឹង និងជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណា និងពិភាក្សា ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. តុលាការបានទទួលបណ្តឹង តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៤១៩១ "ផ" ដ.ង ចុះថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០២៣ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ដែលបានសម្រេចបញ្ជូនជនជាប់ ចោទឈ្មោះ [redacted] មករា ហៅ អាតូល់ ភេទប្រុស អាយុ១៦ឆ្នាំ មកតុលាការដើម្បីជំនុំជម្រះពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈ មានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ ក្រមព្រហ្មទណ្ឌ។

២. ជនជាប់ចោទឈ្មោះ [redacted] មករា បានឆ្លើយថា: ខ្លួន និងឈ្មោះ ឃឿន សុភាន់ ធ្លាប់ធ្វើជាសង្សារជាមួយគ្នា កាលពីមុនមក ប៉ុន្តែខ្លួនមិនដែលស្រឡាញ់គេនោះទេ មានតែគេទេដែលស្រឡាញ់ខ្លួនតែម្នាក់ឯង ព្រោះឈ្មោះ [redacted] សុភាន់ តែងតែមកលេងនៅផ្ទះខ្លួនជាញឹកញាប់ ហើយនាពេលកន្លងមកខ្លួន និងឈ្មោះ [redacted] សុភាន់ តែងតែប្រលែងជាមួយគ្នារហូតមក។ លុះដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ឈ្មោះ [redacted] សុភាន់ បានមកផ្ទះរបស់ខ្លួនស្ថិតនៅ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ពេលនោះខ្លួនកំពុងតែដេកនៅលើអង្រឹងចុចទូរស័ព្ទម្នាក់ឯង ស្រាប់តែឈ្មោះ [redacted] សុភាន់ មកឆក់ទូរស័ព្ទពីដៃរបស់ខ្លួន ព្រោះឃើញខ្លួនកំពុងតែលេងឆាតជាមួយស្រីផ្សេង ខ្លួនក៏បានឆក់ទូរស័ព្ទដៃមកវិញ ស្រាប់តែឈ្មោះ [redacted] សុភាន់ បានខាំកខ្លួនតែម្តង។ ក្រោយមកខ្លួនក៏បានដើរចូលបន្ទប់របស់ខ្លួន ហើយឈ្មោះ [redacted] សុភាន់ ក៏បានមកតាម រួចបានចាប់បោចសក់ និងទះកំភ្លៀងខ្លួន ហើយខ្លួនក៏បានចាប់ដៃរបស់នាងទាំងពីរដើម្បីវាយតបវិញ ស្រាប់តែឪពុករបស់ឈ្មោះ [redacted] សុភាន់ មកដល់ហើយក៏បានហៅសមត្ថកិច្ចមកធ្វើការឃាត់ខ្លួនតែម្តង។

៣. ចម្លើយជនរងគ្រោះឈ្មោះ [redacted] សុភាន់ បានឆ្លើយថា: កាលពីអំឡុងខែកុម្ភៈ ឆ្នាំ២០២៣ ខ្លួនបានស្គាល់ជនត្រូវចោទឈ្មោះ [redacted] មករា ដែលស្នាក់នៅក្បែរបន្ទប់ជួលរបស់ខ្លួនដែរ ហើយជនត្រូវចោទឈ្មោះ [redacted] មករា និងខ្លួនគឺគ្រាន់តែជាអ្នករាប់អានគ្នាធម្មតា តែប៉ុណ្ណោះ ពុំមានចិត្តស្រលាញ់គ្នាទេ។ កន្លងមកជនត្រូវចោទឈ្មោះ [redacted] មករា បានប្រាប់ថាស្រលាញ់ខ្លួន តែខ្លួនតបវិញថា មនុស្សប្រុសម្នាក់មិនអាចស្រលាញ់មនុស្សស្រី០២នាក់បានទេ។ រហូតដល់ថ្ងៃទី ០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោងប្រហែល១០ និង៣០នាទី ប្អូនប្រុសរបស់ខ្លួនបានដើរទៅលេងផ្ទះរបស់ជនត្រូវចោទឈ្មោះ [redacted] មករា ឃើញដូចនេះខ្លួនក៏ដើរសំដៅទៅយកប្អូនត្រឡប់មកផ្ទះវិញ តែពេលទៅដល់ស្រាប់ជនត្រូវចោទឈ្មោះ [redacted] មករា ចាប់ដៃខាងស្តាំរបស់ខ្លួនជាប់ ភ្លាមនោះខ្លួនបានក្រវាសដៃចេញ និងព្យាយាមរើបំរាស់ តែជនត្រូវចោទមិនព្រមលែងដៃរបស់ខ្លួនឡើយ ហើយខ្លួនក៏ស្ទុះទៅចាប់បង្គោលអង្រឹងដែលនៅពីមុខផ្ទះ របស់ជនត្រូវចោទជាប់ តែជនត្រូវចោទព្យាយាមប្រលេះដៃរបស់ខ្លួនចេញពីបង្គោលអង្រឹងនោះ បណ្តាលឱ្យស្នាមជាំលើកដៃទាំងសងខាង។ បន្ទាប់មកជន

ត្រូវចោទឈ្មោះ [redacted] មករា បានទាញខ្លួនផ្តួលទៅលើគ្រែមុខផ្ទះ រួចចាប់អោបខ្លួនហើយលើកបីចូលទៅក្នុងបន្ទប់ដេក របស់ជនត្រូវចោទ ភ្លាមនោះខ្លួនបានស្រែកឱ្យបងជីដូនមួយរបស់ជនត្រូវចោទឈ្មោះ ប៉ែត ដែលកំពុងលាងចាននៅក្បែរនោះ ប៉ុន្តែគាត់ធ្វើជាមិនចាប់អារម្មណ៍។ បន្ទាប់មកជនត្រូវចោទទាញខ្លួនចូលទៅដល់ក្នុងបន្ទប់ដេក ស្រាប់តែជនត្រូវចោទឈ្មោះ [redacted] មករា បានបិទភ្លើងបណ្តាលឱ្យងងឹត តែមិនបានទាញទ្វារបន្ទប់បិទនោះទេ រួចជនត្រូវចោទក៏ចាប់ដៃទាំងសងខាងរបស់ខ្លួនផ្ទឹបទៅលើគ្រែ ហើយបានព្យាយាមថើបថ្ពាល់ទាំងសងខាងរបស់ខ្លួន តែខ្លួនព្យាយាមរើបម្រះ ហើយខាំកញ្ចឹងក ខាងឆ្វេងរបស់ជនត្រូវចោទបណ្តាលឱ្យដាច់សាច់ ប៉ុន្តែជនត្រូវចោទនៅតែបន្តសកម្មភាពដោះខោអាវរបស់ខ្លួនចេញ ហើយភ្លាមនោះឪពុករបស់ខ្លួនបានមកទាន់ រួចក៏ទូរស័ព្ទហៅសមត្ថកិច្ចឱ្យមកឃាត់ខ្លួនជនត្រូវចោទឈ្មោះ [redacted] មករា តែម្តង។

៤. សាក្សីឈ្មោះ [redacted] ប៊ុន ហៅ អាប៉ែត បានឆ្លើយថា: កាលពីថ្ងៃទី២៨ ខែមករា ឆ្នាំ២០២៣ ខ្លួនបានចូលមកធ្វើការជាបុគ្គលិកបូមលូមួយកន្លែងតាមរយៈប្អូនជីដូនមួយរបស់ខ្លួនដែលជាជនត្រូវចោទឈ្មោះ [redacted] មករា ដែលមានទីលំនៅស្ថិតនៅភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។ ចាប់តាំងពីខ្លួនចូលមកធ្វើការបានរយៈពេលប្រហែលកន្លះខែមកនេះ ខ្លួនតែងតែឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ មកលេងនៅកន្លែងធ្វើការរបស់ខ្លួនជាមួយនិងប្អូនប្រុសអាយុប្រហែល០៤ឆ្នាំ ហើយក៏ធ្លាប់ឃើញលេងសើចជាមួយនឹងជនត្រូវចោទឈ្មោះ [redacted] មករា ចំនួន៣ ទៅ ៤ដងមកហើយ។ រហូតដល់ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង០៨ និង០០នាទីព្រឹក ពេលខ្លួនកំពុងអង្គុយលាងចាននៅខាងមុខផ្ទះ ស្រាប់តែឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ បានមកលេងកន្លែងធ្វើការរបស់ខ្លួន បន្ទាប់មកឃើញជនរងគ្រោះឈ្មោះ [redacted] សុភាន់ ដើរមកយកប្អូនប្រុសរបស់នាង និងឃើញជនរងគ្រោះ លេងសើចជាមួយជនត្រូវចោទឈ្មោះ [redacted] មករា ហើយពួកគេបានប្រលែងគ្នាជាច្រើនដងនៅលើគ្រែមុខផ្ទះ។ ឃើញដូច្នេះខ្លួនក៏និយាយណែនាំជនត្រូវចោទថា កុំឱ្យធ្វើអញ្ចឹងព្រោះគេជាស្រី តែជនត្រូវចោទមិនស្តាប់ឡើយ ហើយជនត្រូវចោទបានចាប់អោបជនរងគ្រោះពីក្រោយខ្នង រួចទាញចូលទៅក្នុងបន្ទប់បាត់ទៅ តែពេលនោះខ្លួនមិនបានចាប់អារម្មណ៍ទេ ព្រោះគិតថាពួកគេលេងសើចជាមួយគ្នាតែប៉ុណ្ណោះ លុះក្រោយពីលាងចានរួច ខ្លួនក៏ដើរទៅដេកនៅខាងក្រោយផ្ទះបាត់ទៅ។

៥. តាមការពិនិត្យចម្លើយរបស់ជនជាប់ចោទ, ចម្លើយជនរងគ្រោះ និងចម្លើយសាក្សី តុលាការពិនិត្យឃើញជារួមថា ទោះបីជាជនរងគ្រោះធ្លាប់មានទំនាក់ទំនងពីមុនមកជាមួយជនជាប់ចោទ តែនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ដែលជាថ្ងៃកើតហេតុ ជនជាប់ចោទបានធ្វើសកម្មភាពបំពានផ្លូវភេទលើជនរងគ្រោះពិតមែន ព្រោះសកម្មភាពចាប់អោបជនរងគ្រោះពីក្រោយ, ការទាញខ្លួនផ្តួលទៅលើគ្រែមុខផ្ទះ និងជនជាប់ចោទបានអូសដៃជនរងគ្រោះចូលបន្ទប់ បិទភ្លើងក្នុងបន្ទប់នៅតែពីរនាក់ក្នុងបន្ទប់ស្ងាត់ មិនមែនជាសកម្មភាពប្រលែងគ្នាលេងនោះទេ។ ទោះបីជាជនជាប់ចោទបានឆ្លើយបដិសេធពីចេតនាទុច្ចរិតរបស់ខ្លួន ប៉ុន្តែនេះគ្រាន់តែជាចម្លើយដោះសាររបស់ជនជាប់ចោទប៉ុណ្ណោះ។ លើសពីនេះ ជនរងគ្រោះមានស្លាកស្នាមជាំនៅលើកដៃ ហើយជនជាប់ចោទមានស្លាកស្នាមជាំនៅលើក គឺអាចបញ្ជាក់បានថា ការប្រតាយប្រតប់គ្នា ពិតជាមានពិតមែន ដែលចំនុចទាំងនេះ មានភាពស៊ីសង្វាក់គ្នាទៅនឹងរបាយការណ៍សំយោគលេខ ០៤/២០២៣ វ.ប.ក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២៣ របស់ការិយាល័យប្រឆាំងការជួញដូរមនុស្ស នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ អាចបញ្ជាក់បានថា ជនជាប់ចោទឈ្មោះ [redacted] មករា ហៅ អាឆ្វល់ ភេទប្រុស អាយុ១៦ឆ្នាំ ពិតជាប្រព្រឹត្តអំពើ ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ប្រាកដមែន។



Scanned with CamScanner

៦. អំពើរបស់ជនជាប់ចោទ ធ្វើឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូរ និងរូបកាយរូបវន្ត សន្តិសុខសង្គម សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ជាអំពើល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ ក្រមព្រហ្មទណ្ឌ។

៧. ជនជាប់ចោទជាជនដែលមាននីតិសម្បទាគ្រប់គ្រាន់ ដោយពុំមានសញ្ញាណណាមួយ ដែលនាំឲ្យមានមន្ទិលសង្ស័យថា ជននេះមានវិបល្លាសស្មារតីក្នុងពេលប្រព្រឹត្តបទល្មើសទេ។ ជននេះមានការពិចារណាយល់ ដឹងអំពីផលវិបាកកើតចេញពីអំពើរបស់ខ្លួន ដែលស្ថិតនៅក្នុងលក្ខខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ។

៨. សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ មានមូលហេតុ និងមូលដ្ឋានគ្រប់គ្រាន់បញ្ជាក់ពីពិរុទ្ធភាព របស់ជនជាប់ចោទ ព្រោះសកម្មភាពមួយចំនួនរបស់ជនជាប់ចោទមានការប៉ះពាល់ដល់ផ្នែកផ្លូវភេទដូចជា ការចាប់អោបជនរងគ្រោះពីក្រោយ, ការទាញខ្លួនផ្តួលទៅលើគ្រែមុខផ្ទះ និងជនជាប់ចោទបានអូសដៃជនរងគ្រោះចូលបន្ទប់ បិទរឿងក្នុងបន្ទប់ នៅតែពីរនាក់ក្នុងបន្ទប់ស្ងាត់ ដូចនេះមិនអាចបញ្ជាក់ពីការយល់ព្រមរបស់ជនរងគ្រោះនោះទេ គឺជនជាប់ចោទមានចេតនាប៉ះពាល់ផ្លូវភេទលើជនរងគ្រោះពិតមែន។ តំណាងអយ្យការនៅតែតម្កល់បទចោទប្រកាន់លើជនជាប់ចោទពីបទ: ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា ២៧ និងមាត្រា ២៤១ ក្រមព្រហ្មទណ្ឌ និងប្តឹងសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។ តុលាការយល់ឃើញថា មានភាពត្រឹមត្រូវ គប្បីតុលាការលើកមកពិចារណា។

៩. ជនជាប់ចោទឈ្មោះ [redacted] មករា កើតថ្ងៃទី០១ ខែមករា ឆ្នាំ២០០៧ ជាអនីតិជន ដូចនេះតុលាការនិងធ្វើការសម្រេចផ្តន្ទាទោសអោយបានត្រឹមត្រូវតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ។

១០. វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ ៥០២ រ.វ.ត/២៣ ចុះថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២៣ របស់សាលាដំបូង និងអយ្យការអម សាលាដំបូងរាជធានីភ្នំពេញ រួមមាន: ទូរស័ព្ទចំនួន ០១ (មួយ) គ្រឿង ម៉ាក OPPO ពណ៌ទឹកប៊ិច បែកអេក្រង់ គុណភាពចាស់ (មិនដំណើរការ) ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដែលមានការទទួលស្គាល់ផ្តិតមេដៃពីជនសង្ស័យឈ្មោះ [redacted]មករា និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជីទទួលបន្ទុកឃ្លាំងវត្ថុចាប់យក។ ត្រូវប្រគល់ជូនម្ចាស់ដើមវិញតាមមាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

## ហេតុដូច្នេះសម្រេច

**១. ផ្តន្ទាទោសជនជាប់ចោទ៖ ឈ្មោះ [redacted] មករា ហៅ អាឆ្វល់** ភេទប្រុស អាយុ១៦ឆ្នាំ ជនជាតិខ្មែរ (មានអត្តសញ្ញាណខាងលើ) ដាក់ពន្ធនាគារកំណត់ចំនួន **០៣ (បី) ឆ្នាំ ០៦ (ប្រាំមួយ) ខែ** ពីបទ: **ប៉ុនប៉ងរំលោភសេពសន្ថវៈមានស្ថានទម្ងន់ទោសទាក់ទងនឹងជនរងគ្រោះ** ប្រព្រឹត្តនៅ ផ្ទះគ្មានលេខ ភូមិតាឡី សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ តាមបញ្ញត្តិមាត្រា **២៧** និងមាត្រា **២៤១** ក្រមព្រហ្មទណ្ឌ។

២. វត្ថុចាប់យកមានដូចក្នុងកំណត់ហេតុទទួលវត្ថុចាប់យក (១) លេខ **៥០២ រ.វ.ត/២៣** ចុះថ្ងៃទី៣ ខែ មីនា ឆ្នាំ២០២៣ រួមមាន: ទូរស័ព្ទចំនួន ០១ (មួយ) គ្រឿង ម៉ាក OPPO ពណ៌ទឹកប៊ិច បែកអេក្រង់ គុណភាពចាស់ (មិនដំណើរការ) ត្រូវបានវេចខ្ចប់ក្នុងស្រោមសំបុត្របិទជិត ចំនួន០១ (មួយ) ពណ៌ស ដែលមានការទទួលស្គាល់ផ្តិតមេ



Scanned with CamScanner

ដែលពីជនសង្ស័យឈ្មោះ [redacted] មកវា និងមានការចូលរួមចុះហត្ថលេខាពីមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងក្រឡាបញ្ជី ទូលបន្ទុកឃ្លាំងវត្ថុចាប់យក។ ត្រូវប្រគល់ជូនម្ចាស់ដើមវិញតាមមាត្រា **៣៥៤** នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាអសាធារណៈ នៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២៤ កំបាំងមុខជនជាប់ចោទ និង ប្រកាសជាអសាធារណៈ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២៤ ។

បើកសិទ្ធិឱ្យប្តឹងទាស់ និងប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

| **ក្រឡាបញ្ជីសវនាការ** | **ចៅក្រមប្រឹក្សា** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សាជំនុំជម្រះ** |
|---|---|---|---|
| **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** | **ហត្ថលេខា និងត្រា** |

[redacted]

---

"បានចម្លងត្រឹមត្រូវតាមច្បាប់ដើម"។

ថ្ងៃ ចន្ទ ១២កើត ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែមករា ឆ្នាំ២០២៤

**ក្រឡាបញ្ជី**

[redacted]

**បានឃើញ**

**ប្រធានក្រុមប្រឹក្សាជំនុំជម្រះ**

[redacted]



Scanned with CamScanner